# ១២- រឿង បុរសទំពែកបួននាក់

កាលពីព្រេងនាយ នៅភូមិមួយ មានបុរសទំពែក ៤នាក់ ឈ្មោះឃុត ១ស៊ីម១ គំ ១សុខ ១ ។ បុរសទំពែក ៤នាក់នោះ ជាមនុស្សកំសត់ទុគ៌តណាស់ ក្មេងៗ និងអ្នកស្រុកអ្នកភូមិតែងស្រែកហៅគាត់ថា " តាប៉ិទំពែក ! តាប៉ិទំពែក ! " ជារាល់ពេល ។

ថ្ងៃមួយ បុរសទំពែកទាំង ៤ នាក់បានជំនុំស្រុះស្រួលមូលមតិគ្នាថា " យើងទាំងអស់គ្នា ពុំអាចរស់នៅក្នុងកន្លែងនេះយូរទៅទៀតបានទេ ខ្មាសអ្នកនគរខ្លាំងណាស់ ព្រោះអ្នកផង គេមើលងាយយើងពន់ប្រមាណ ដូច្នេះត្រូវយើងចេញទៅរកគ្រូមើលជំងឺ ដើម្បីធ្វើឱ្យសក់ក្បាលយើងដុះឡើងដូចជនឯទៀត " ។ ជនទំពែក ៤ នាក់ក៏ស្រុះស្រួលព្រមព្រៀងគ្នាប្រុងប្រៀបរៀបចំគ្រឿង ប្រដាប់ប្រដាធ្វើដំណើរ រួចក៏ធ្វើដំណើរចេញទៅកាត់ស្រុកធំតូច កាត់ភូមិកាត់ស្រែ ស្វែងរកពេទ្យហ្មមេមត់ដ៏ប៉ិនប្រសប់ ដែលអាចធ្វើឱ្យក្បាលខ្លួន ដុះសក់ឡើងវិញបាន ប៉ុន្តែបុរសទំពែក ៤ នាក់ឥតបានជួប នឹងជនដែលមានរឹទ្ធិ អំណាចដូច្នេះសោះ ។

ជនទំពែក ៤ នាក់ក៏ធ្វើដំណើរតទៅទៀត លេចវាលចូលព្រៃលេចព្រៃចូលវាល លុះត្រាតែទៅដល់ព្រៃហេមពាន្ត ដែលជាកន្លែងមហាឫសីមួយ ។ បុរសទំពែក ៤នាក់ក៏ចូលទៅក្នុងអាស្រមតាឫសីនោះ ឱនកាយថ្វាយបង្គំដោយសេចក្តីគួរសម ។ តាឫសីសួរថា តើអ្នកទាំង ៤នាក់អញ្ជើញមកពីប្រទេសណា ? មានការអ្វី ? " ។ បុរសទំពែក ៤ នាក់ក៏ឆ្លើយប្រាប់តាឫសីថា " ជម្រាបលោកតា យើងខ្ញុំទាំងអស់គ្នាមកពីប្រទេសឆ្ងាយណាស់ ដោយហេតុតែយើងខ្ញុំ ទំពែកទាំងអស់គ្នា ពួកអ្នកស្រុកទាំងឡាយ ចេះតែសើចចំអកឡកឡឺយ ឱ្យជារាល់ពេលរាល់វេលា ទើបយើងខ្ញុំអត់ទ្រាំពុំបានចេញមកស្វែងរកគ្រូពេទ្យ ដែលចេះធ្វើក្បាលយើងខ្ញុំឱ្យដុះសក់ដូចជាជនឯទៀតឡើង ប៉ុន្តែយើងខ្ញុំឥតបានជួបប្រទះគ្រូពេទ្យណាមួយសោះ អាស្រ័យហេតុនេះបានជាយើងខ្ញុំខំធ្វើដំណើរទាល់តែមកដល់ អាស្រមលោកតានេះ សូមលោកតាអាណិតអាសូរយើងខ្ញុំ ជួយធ្វើយើងខ្ញុំឱ្យបានដុះសក់ដូចគេឯងទៀតឡើង ។

តាបសីក៏ឆ្លើយថា " ចុះមានលំបាកអ្វី ចៅទាំងឡាយអើយ ! នៅទីនេះមានត្រពាំងទឹកស័ក្តិសិទ្ធិមួយ ចូរអ្នកទាំងឡាយទៅមុជទឹកត្រពាំងនោះចុះ ប៉ុន្តែ ត្រូវអ្នកទាំងអស់គ្នាមុជតែម្តងបានហើយ កុំមុជច្រើនដងឱ្យសោះ " ។

កាលបើបានឮតាបសប្រាប់ដូច្នេះហើយ បុរសទំពែក ៤ នាក់ក៏កើតសេចក្តីរីករាយជាក្រៃលែង ហើយចុះទៅមុជទឹកក្នុងត្រពាំងនោះទាំងអស់គ្នា ។ មួយសន្ទុះក្រោយមក បុរស ៤ នាក់ក៏ងើបចេញពីត្រពាំងទឹកឡើង ហើយនៅលើក្បាលរៀងខ្លួនក៏មានដុះសក់យ៉ាងក្រាស់ ខ្មៅរលោង ។ លោកតាទំពែកយើង ៤ នាក់ក៏ខំសម្លឹងមើលក្បាលគ្នាទៅវិញទៅមក ហើយលាន់មាត់សរសើរតែរៀងខ្លួន ។

នៅខណៈនោះ បុរសទំពែក៤ នាក់ក៏កើតមានចិត្តលោភពន់ប្រមាណទើបជំនុំគ្នាថា " យើងទាំងអស់គ្នាបានមុជទឹកនេះត្រឹមតែម្តងប៉ុណ្ណោះ ឃើញថាបានល្អប៉ុណ្ណោះហើយ ចុះទម្រាំបើយើងមុជច្រើនដងទៅទៀត តើយើងនឹងល្អយ៉ាងណាទៅ តាបសប្រហែលជាមិនចង់ឱ្យយើងល្អណាស់ទេមើលទៅ បានជាបង្គាប់ឱ្យយើងមុជទឹកតែម្តងម្នាក់ដូច្នេះ គួរតែយើងទៅមុជទឹកឱ្យបានម្តងម្នាក់ទៀត " ។

បន្ទាប់មក បុរសទំពែក៤ នាក់ក៏ស្រុះស្រួលគ្នា ហើយបបួលគ្នាទៅមុជទឹកសាជាថ្មីទៀត ប៉ុន្តែ ម្តងនេះកាលបើងើបឡើងពីទឹកភ្លាមបុរសកំសត់យើងជ្រុះបាត់សក់អស់នៅសល់តែក្បាលទំពែករលីងនិញ ដូចកាលពីដើមវិញ ។ អាស្រ័យហេតុនេះបុរសទំពែក៤ នាក់ក៏កើតសេចក្តីឈឺចាប់ព្រួយចិត្តជាក្រៃលែង ហើយក៏បបួលគ្នាមុជទឹកម្តងទៀត ប៉ុន្តែ លុះងើបឡើងក្បាលនោះរឹតតែទំពែករលីងជាងមុនទៅទៀតថែមទាំងភ្លឺរលោងឡើង ។ កាលពីពេលមុន បុរសទំពែក ៤ នាក់គ្រាន់មានសក់ពីរ បីសរសៃដុះនៅលើក្បាល ប៉ុន្តែ កាលបើមុជទឹកអស់ចំនួនបីលើកដូច្នេះហើយ ក្បាលបុរសទំពែកទាំង ៤ នាក់ឡើងរលោងស្រិលដូចជាក្បាលសត្វត្រដក់ ។

បុរសទំពែក ៤ នាក់អស់សង្ឃឹមក៏ដើរចេញពីទីនោះយំត្អូញត្អែរថា " ការនេះបណ្តាលមកពីយើងមិនប្រតិបត្តិតាមដំបូន្មានតាបស ដូច្នេះត្រូវតែយើងត្រឡប់ទៅជួបតាបសវិញហើយអង្វរលន់តួសូម ឱ្យគាត់ជួយធ្វើក្បាលយើង បើមិនបានទៅជាល្អទេ ហោចណាស់ក៏ឱ្យបាននៅប្រហែលពីដើមវិញកុំឱ្យរលីងរលោងស្រិលដូចក្បាលត្រដក់ដូច្នេះវាអាក្រក់ណាស់ " ។



លុះជំនុំគ្នាដូច្នេះហើយ បុរសទំពែកទាំងឡាយក៏ធ្វើដំណើរត្រឡប់ទៅកាន់លំនៅតាបសវិញ ។ តាបសសួរថា " តើមានការអីចៅទាំងឡាយ ? " ។ ចៅទំពែកក៏ឆ្លើយថា " លោកតាជាទីគោរពយើងខ្ញុំសូមអង្វរលោកតា សូមលោកតាមេត្តាត្រាប្រណីទោសដល់យើងខ្ញុំផង ត្បិតយើងខ្ញុំពុំបានធ្វើតាមបង្គាប់លោកតា បានជាក្បាលយើងខ្ញុំរឹតតែរលីងជាងថ្ងាសទៅទៀត យើងខ្ញុំសូមអង្វរលោកតា ឱ្យជួយធ្វើយ៉ាងណាឱ្យក្បាលយើងខ្ញុំទាំងអស់គ្នា បើមិនបានល្អ ក៏សូមឱ្យតែនៅប្រហែលពីដើមវិញក៏បានដែរ " ។

តាបសឆ្លើយតបវិញថា " ឱចៅទាំងឡាយអើយ អាត្មាពុំអាចញុំាងខ្លួនអ្នកឱ្យទៅជាយ៉ាងម៉េចបានទៀតទេ កំហុសរបស់អ្នកជាភស្តុតាងបង្ហាញឱ្យដឹងថា អ្នកទាំងឡាយពុំអាចប្រតិបត្តិតាមដំបូន្មានពិបាកៗ បានទេ តែចូរអ្នកពិចារណាដូច្នេះថា " សេចក្តីប្រាថ្នាហួសប្រមាណបណ្តាលឱ្យហិនហោច ។ ណ្ហើយ ! ចូរអ្នកត្រឡប់ទៅស្រុកអ្នកវិញទៅគ្មានមធ្យោបាយអ្វីអាចផ្លាស់ប្តូររូបអ្នកបានតទៅទៀតទេ " ។

បុរសទំពែកទាំង ៤ នាក់ក៏ត្រឡប់ទៅស្រុកវិញ ហើយម្តងនេះអ្នកស្រុករឹតតែពោលចំអកឡកឡឺយឱ្យជាងមុនទៅទៀត ។

បុរសទំពែកទាំង ៤ នាក់ ក៏រឹតតែខ្មាសលើសដើម ហើយរកមេមត់យ៉ាងពូកែៗល្បីល្បាញឱ្យធ្វើប្រេង ក្រមួន និងថ្នាំត្រាំស្មៅ ឬឈើដ៏មានគុណភាពយ៉ាងប្រសើរៗ មកលាបមករឹតច្របាច់លើសាច់ក្បាលរបស់ខ្លួន ព្រមទាំងសូត្រមន្តអាគមគាថាផ្សំជាមួយផង តែទោះបីខំធ្វើយ៉ាងណា ក៏ក្បាលនៅតែគ្មានដុះសក់ដដែលរលោងស្រិល ដូចជាគ្រាប់គ្រួសសមុទ្រ ។ នេះគឺជាផលកម្មពិតប្រាកដ ដោយគាត់បានប្រព្រឹត្តអំពើកំហុសអ្វីមួយពីជាតិមុន ឬ មួយកាលពីជាតិមុនគាត់ប្រកបរបររកស៊ីកាត់សក់ហើយបំពេញករណីយកិច្ចរបស់ខ្លួនពុំបានត្រឹមត្រូវ ។

ទោះបីមានអត្តភាពគួរឱ្យអាម៉ាស់ដូចពោលហើយក៏ដោយក៏បុរសទំពែក ៤ នាក់នោះមានចិត្តដូចជាជនឯទៀតដែរ គឺគាត់មានចិត្តប្រាថ្នាជាខ្លាំង ចង់យកក្បាលគាត់ទៅកើយលើទ្រូងនារីជាទីសប្បាយ ប៉ុន្តែគ្មានស្រីណាម្នាក់ព្រមស្រឡាញ់បុរសទំពែកទាំង ៤ នាក់នោះសោះ ដោយហេតុតែគាត់មានលលាដ៍ក្បាល រលីងរលោងដូចត្រឡោកដែលគេខាត់ដើម្បីទុកដួសទឹកផឹក ។

ហេតុនេះហើយ បានជាគេឃើញបុរសទំពែកមានវ័យចាស់ៗ ណាស់ហើយ ប៉ុន្តែ ពុំទាន់មានប្រពន្ធនៅឡើយហើយទោះបីគាត់មានអាយុចាស់ប៉ុនណាក៏ដោយ គាត់នៅតែខំស្វែងរកប្រពន្ធឥតឈប់ឈរ ។ ប៉ុន្តែ ម្តងនេះបុរសទំពែក ៤ នាក់ចេញស្វែងរកប្រពន្ធដោយចិត្តងប់ឈ្លប់តែម្តង គេពុំដឹងថា តើមានហេតុយ៉ាងណាទេ គេគ្រាន់តែដឹងថានេះ គឺជាវត្ថុបំណងរបស់គាត់យូរណាស់មកហើយ ហើយការនេះក៏ទៅជាទម្លាប់មួយរបស់ពួកគាត់ ។

ព្រេងវាសនាបាននាំគាត់ទាំង ៤នាក់ ឱ្យមកជួបគ្នាហើយស្រឡាញ់គ្នាណាស់ បានស្បថគ្នាថាមិនត្រូវរស់នៅបែកគ្នាឡើយ ។ បើមួយទៅណា អ្នកឯទៀតក៏ត្រូវទៅតាមដែរ ។ ហេតុនេះហើយបានជាគេឥតដែលឃើញលេចបុរសទំពែកមួយចេញពីច្រកចង្អៀត ដោយឥតឃើញទំពែកបីនាក់ទៀតមកតាមក្រោយឡើយ ។

គេតែងឃើញឈ្មោះ យុត ដែលគាត់មានរាងខ្ពស់ស្គមស្លៀកខោខ្លី ដើរមុខគេ ហើយដើរលឿនដាច់មិត្តគាត់ទាំងអស់ ទោះបីគាត់ខំប្រយ័ត្នកុំឱ្យដើរលឿនចោលគេក៏ដោយ ។ បន្ទាប់មកគេឃើញឈ្មោះ ស៊ុម ដែលមានមាឌតូចធាត់ ខំដើរទីងទាំងៗ តាមយុតដូចសត្វអណ្តើក ។ បន្ទាប់មកទៀតគេឃើញគំនិង សុខ ដើរទន្ទឹមស្មាគ្នា ។ ពីរនាក់នេះជាមនុស្សជជែកឡូឡាដាក់ត្រចៀកគ្នា ព្រោះត្រចៀកពុំសូវបាន ។

ថ្ងៃមួយ យុតនិយាយទៅកាន់សំឡាញ់ខ្លួនថា " យើងពុំអាចរកប្រពន្ធនៅក្នុងស្រុកនេះបានទេ ទោះចាស់ក្តី ក្មេងក្តី ស្រីៗនៅក្នុងស្រុកនេះ គេមាក់ងាយមាក់ថោក យើងទាំងអស់ដោយហេតុតែក្បាលយើងគ្មានដុះសក់ ប៉ុន្តែ បើយើងទៅកាន់តំបន់មួយទៀត



ប្រហែលជាយើងមានសំណាងជាងនេះ ហើយបើមាននរណាថាយើងចាស់ យើងអាចឆ្លើយទៅវិញថា សក់យើងវាជ្រុះព្រោះជាធម្មតារបស់ជនដែលមានអាយុច្រើននឹងមានការព្យាយាមគិតគូរច្រើន កាលបើដូច្នេះ អ្នកស្រុកមុខជាយល់ថា យើងជាអ្នកមានការសិក្សាច្រើន ហើយជឿថាយើងជាអ្នកប្រាជ្ញផង " ។

នៅពេលនោះ បុរសទំពែក ៤នាក់ ក៏ពិភាក្សាគ្នាអស់រយៈពេលយ៉ាងយូរ ហើយព្រមព្រៀងគ្នាយល់ថា យើងកុំនឹកព្រួយថា ក្រែងស្រីនៅស្រុកឯទៀតមិនស្អាតដូចជាស្រីនៅក្នុងស្រុកកំណើតរបស់ខ្លួន ។ ស៊ុមខ្លាចអស់កម្លាំង ដោយធ្វើដំណើរឆ្ងាយបាននិយាយអង្វរយុតកុំឱ្យដើរលឿនពេក ។ សុខបានរំលឹកយ៉ាងម៉ឺងម៉ាត់នូវពាក្យសម្បថថា " យើងមិនត្រូវបែកគ្នាឱ្យសោះ មិនត្រូវមានប្រពន្ធចោលគ្នា ឬក៏ត្រូវតែមានប្រពន្ធទាំងអស់គ្នានៅក្នុងស្រុកណាមួយជាមួយគ្នា " ។

អាស្រ័យហេតុនេះ វេលាព្រឹកមួយ ពេលមុនថ្ងៃរះពេញពន្លឺគេឃើញបុរសទំពែក ៤ នាក់ មានដៃកាន់ដំបងនិងស្ពាយថង់មួយៗម្នាក់ស្លៀកសំពត់ថ្មីៗ ដើរចេញពីភូមិទៅកាន់ផ្លូវប្រឡាយមាត់ទន្លេ ធ្វើដំណើរតម្រង់ទៅទិសខាងជើង ។ ម្តងនេះគេឃើញបុរសទំពែកដើរមួយៗ ដើម្បីអនុគ្រោះដល់ស៊ុមឱ្យគាត់ដើរទាន់ផង ។ បុរសទំពែកមានខ្នងកោង ហើយគាត់ដើរទប់ខ្លួននឹងឈើច្រត់ ប៉ុន្តែ គាត់នៅមានចិត្តចង់សប្បាយពន់ប្រមាណ ហើយជាធម្មតា គេតែងឃើញយុតដើរលឿនចោលគេទាំងអស់ រួចមួយស្ទុះ ក្រោយមកទើបលេចឃើញស៊ុមខំដើរខ្វាសៗ ស្រែកហៅយុតឱ្យបង្អង់ជំហាន ។

មិនយូរប៉ុន្មានបុរសទំពែក ៤ នាក់បានដើរទៅដល់ភូមិមួយ បបួលគ្នាចូលទៅក្នុងភូមិនោះ ជាទេសកាលអ្វី ក្នុងថ្ងៃនោះ នៅក្នុងភូមិនោះមានកើតរឿងហេតុមួយយ៉ាងធំ គឺស្រីមេម៉ាយម្នាក់ ចាប់បានបុរសម្នាក់កំពុងដេកជាមួយនឹងកូនក្រមុំគាត់ ហើយគាត់ក៏ប្តឹងពុំសុខចិត្តនឹងបុរសនោះ ។ ដើម្បីនឹងសម្រាលកំហុសរបស់ខ្លួនបន្តិច បុរសខិលបានឆ្លើយដោះសារទៅនឹងចៅក្រមថា " នាងក្រមុំនេះ ជាសហាយរបស់ខ្លួនយូរណាស់មកហើយ " ប៉ុន្តែ នាងនោះបានឆ្លើយបដិសេធជាដាច់អហង្ការថា ខ្ញុំឥតបានស្គាល់អា

មនុស្សពាលនេះទេ វានេះជាមនុស្សកុហកឥតខ្មាស វាបានលួចលបមកក្នុងបន្ទប់ខ្ញុំដូចជាចោរ នៅពេលខ្ញុំកំពុងគេងលក់ ហើយបានប្រើកម្លាំងបាយបង្ខំខ្ញុំឱ្យព្រមធ្វើតាមបំណងវា ទោះបីខ្ញុំខំនិយាយអង្វរយ៉ាងណាក៏វាពុំព្រមស្តាប់សោះឡើយ ។

ឮដូច្នោះ ចៅក្រមក៏មានចិត្តអល់ឯកពុំអាចរកសេចក្តីពិតបាន ។ ប៉ុន្តែ នៅខណៈនោះស្រាប់តែលេច យុត គំ ស៊ុម សុខ ដើរចូលមកយ៉ាងមួយៗ ហើយបែបសង្រួមខ្លួនដូចជាព្រះសង្ឃនិមន្តទៅប្រោសសត្វ ហើយមហាជនដែលឈរនៅជុំវិញរោងជំនុំ ក៏បើកផ្លូវយ៉ាងធំឱ្យបុរសទំពែកចូល ព្រមទាំងសំដែងសេចក្តីគួរសមដល់បុរសទំពែកទាំងនោះផង ព្រោះគេយល់ថា បុរសទំពែកនេះជាបេសកជនរបស់ព្រះពុទ្ធ ហើយជាចៅក្រមធំបំផុត ។

កាលបើគេសម្លឹងមើលសាច់ឈាម និងក្បាលទំពែកសព្វគ្រប់ទៅគេក៏ជឿថា បុរសទំពែក ជាមនុស្សចេះដឹងយ៉ាងជ្រៅជ្រះទើបចៅក្រមប្រគល់កន្លែងខ្លួនឱ្យគាត់អង្គុយវិញ ។

កាលបានអង្គុយស្រួលបួល ហើយបានដឹងកិច្ចការនោះសព្វគ្រប់បុរសទំពែកទាំង ៤ នាក់ ក៏អង្គុយនៅស្ងៀមសញ្ជឹងគិតមួយសន្ទុះ រួចយុតក៏ចាប់និយាយមុនគេឡើងថា :

- ទំពក់វាទៅ ទើបញ៉ៅវាមក ។

បន្ទាប់មកគំនិយាយថា :

- មានប្រឡាយទើបទឹកវាហូរ ។

បន្ទាប់មកទៀតស៊ុមនិយាយថា :

- តែកន្លែងណាមានដុះត្រឡាច វាមានដុះឃ្លោក ។

នៅទីបំផុតសុខនិយាយថា :

- កន្លែងណាឆ្កែវាធុំក្លិនទឹកនោម វាលើកជើង ។



កាលបើពោលពាក្យមួយឃ្លាម្នាក់ ដោយពុំមានអត្ថន័យដូច្នេះរួចហើយបុរសទំពែកក៏បង្គាប់ឱ្យរៀបការបុរសស្ត្រីពីរនាក់នោះទៅ ។ នៅពេលនោះ អ្នកស្រុកនិងចៅក្រមទាំងឡាយ ក៏ស្ងើចសរសើរ នូវគតិបណ្ឌិតនិងការឈ្លាសវៃ នៃចៅក្រមទំពែកជាច្រើន ហើយក៏បបួលគ្នាជូនវត្ថុជារង្វាន់ដល់គាត់ទាំងអស់គ្នាជាច្រើន ។ ឯម្តាយនៃស្ត្រីមានរឿងក៏ពេញចិត្តនឹងការកាត់សេចក្តីនេះ ហើយក៏ចូលទៅសំពះសំដែងអំណរគុណដល់បុរសទំពែកទាំង ៤ ។

ប៉ុន្តែ ទោះបីមានល្បីឈ្មោះដូច្នេះ ក៏នៅតែស្រីៗ ពុំព្រមស្រឡាញ់បុរសទំពែកទៀត ។ ទើបបុរសទំពែកទាំងអស់គ្នានឹកឃើញដល់ស្រីមេម៉ាយ ដែលខ្លួនបានកាត់ក្តីឱ្យពីថ្ងៃមុន ហើយយុតក៏ផ្តើមនិយាយថា :

- គឺជាស្រីដែលមានចរិយាសមរម្យណាស់ ។

គំបន្តថា :

- ជាស្រីមានការអប់រំប្រកបដោយបែបបទល្អ ។

សុខបន្ថែមថា :

- ពិតមែនតែស្គមបន្តិច ប៉ុន្តែមានសម្រស់ ។

ស៊ុមបញ្ចប់ថា :

- ពុំដឹងជាហេតុអ្វី កាលបើឃើញគាត់ខ្ញុំចេះតែនឹកដល់ម្តាយខ្ញុំ ដែលជាការអាចឱ្យខ្ញុំទាយបានថា គាត់ជាស្រីប្រសប់ចាត់ចែងកិច្ចការក្នុងផ្ទះ មានចិត្តសន្តោស ហើយមានសំដីទន់ផ្អែម ចេះថ្នាក់ថ្នមបមបំពេផង ។

បន្ទាប់ពីមានយោបល់រៀងខ្លួនដូច្នេះហើយ ទំពែកទាំង ៤ ក៏សម្រេចចិត្តថាត្រូវទៅដណ្តឹងស្រីមេម៉ាយនោះធ្វើជាប្រពន្ធ ។ ស្រីមេម៉ាយនោះឈ្មោះយាយអៀង ។ គាត់ចាស់ណាស់ទៅហើយធ្មេញក៏បាក់ សាច់ក៏ឡើងជ្រីវជ្រួញយុរយារ សម្បុរស្រអាប់មើលទៅឃើញដូចសំបកមង្ឃុតស្ងួត ។

និយាយពីយាយអៀងមេម៉ាយ កាលបើបានឮដំណឹងដូច្នេះគាត់ក៏នឹកក្នុងចិត្តថា :

អញនេះជាស្រីដំបូងបង្អស់ក្នុងប្រទេសខ្មែរដែលត្រូវបានជួបការសប្បាយអស្ចារ្យដូច្នេះ ។ ពីដើម អញស្មានថា អញនេះជាមនុស្សចាស់រយាក ហើយអាក្រក់ក្រៃលែងអស់មាននរណា មកស្នេហាអញហើយ ព្រោះមានតែឆ្កែទេ ដែលនៅដេញតាមព្រុះអញ បើចំណែកឯក្មេងអនាថាវិញ កាលណាវាឃើញអញវាបបួលគ្នារត់ចេញឆ្ងាយដោយវាស្រែកថាអញជាយាយចាស់កំណាច ឥឡូវស្រាប់តែឮដំណឹងថាបុរសទំពែក ៤ នាក់ចូលមកដណ្ដឹងអញរៀបការ គឺដណ្ដឹងទាំង ៤ នាក់ព្រមគ្នាតែម្ដង ឮដូច្នេះអញសប្បាយចិត្តណាស់ ប៉ុន្តែទាស់តែពុំទាន់ប្រាកដ តើអញត្រូវរើសយកនរណាអែះ ? បើគ្មានអ្នកណាមួយល្អជាងគេសោះគឺ :

" ជនទីមួយមានមាឌធំ ប៉ុន្តែ ស្គមដូចជាសំបកសណ្ដែកស្ងួត " ។ " ជនទីពីរធាត់ ប៉ុន្តែ ជើងខ្លីដូចជាសត្វទុង " ។

" ចំណែកពីរនាក់ទៀត មានរាងសមសួនបន្តិច ប៉ុន្តែថ្លង់មើលតែស៊ុតខះរឹងម្យ៉ាងទៀត បើអញទទួលយកមួយធ្វើប្ដី មុខជាអ្នកឯទៀតខឹងសម្បានឹងអញពុំខាន អញមិនចង់ធ្វើឱ្យគេអាក់អន់ចិត្ត នឹងអញសោះ ដូច្នេះអញត្រូវតែទទួលយកទាំង ៤ នាក់" ។

ទើបគាត់នឹកទៀតថា :

មួយនាក់សម្រាប់ដងទឹកឱ្យអញ មួយនាក់ទៀតសម្រាប់ពុះឧសជនទីបីសម្រាប់ទៅរកដំឡូងនិងបន្លែ ជនទីបួនសម្រាប់បង្កាត់ភ្លើងដាំបាយចំណែកអញៗ អង្គុយនៅស្ងៀម ធ្វើការតែបន្តិចបន្តួច ។

ដូច្នេះ យុតដែលមានជើងវែងៗយាយអៀងតម្រូវឱ្យរែកទឹកពីទន្លេមកដាក់ពាងស៊ីមដែលមានទំនងជាអ្នកល្មោភតម្រូវឱ្យធ្វើបាយ ។ ចំណែកឯគំនិងសុខ ជាអ្នកមានត្រចៀកធ្ងន់ ហើយដែលយាយអៀងយល់ថា ជាមនុស្សធ្វើឱ្យគាត់នឿយហត់កម្លាំង



ព្រោះត្រូវនិយាយខ្លាំងៗទើបស្ដាប់បាន គាត់បានតម្រូវឱ្យទៅព្រៃរកឧសរកវល្លិ និងជីកដំឡូង ។

ទោះបីចាត់ការដូច្នេះក៏ដោយ ក៏គេនៅតែឮមាត់យាយអៀងស្រែកសន្ធាប់ជេរប្ដីគាត់ទាំង ៤ តាំងពីព្រលឹមទល់ព្រលប់គាត់បន្ទោសថាធ្វើការល្វើយៗ ទឹមទាមៗ ហើយគាត់ដកដង្ហើមធំឥតឈប់ឈរសោះ ។

គាត់ពោលថា " កាលគាត់នៅពីក្មេង មនុស្សប្រុសស្រឡាញ់គាត់ខ្លាំងណាស់ ហើយគេជាមនុស្សប៉ិនប្រសប់គ្រប់យ៉ាង " ។

ដូច្នេះ តាចាស់ៗ ទាំង ៤ ឥតស្គាល់ពេលសម្រាកសោះ ។ យាយអៀងតែងរិះរករឿងប្រើបុរសទំពែកឥតមានល្ហែ ។ អាស្រ័យហេតុនេះ ហើយបានជាយុតទៅដងទឹកនៅអង្គុយត្រែតត្រតៗ ឯមាត់ទន្លេ ចំណែកគំនិងសុខទៅនៅតំអក់ តំអែក្នុងព្រៃ ។ អ្នកដែលអភ័ព្វជាងគេគឺស៊ីម ព្រោះស៊ីមនៅផ្ទះជានិច្ច ។ យាយអៀងស្ដីបន្ទោសច្រាសឆ្អេះឱ្យគាត់តាំងពីព្រលឹមទល់ព្រលប់ឥតឈប់ឈរ ។ ហេតុនេះ ស៊ីមក៏ទៅជាមនុស្សគេមើលលែងស្គាល់ ខ្លួនឡើងស្គម សាច់ស្បែកមុខឡើងស្ងួតក្រៀមដោយសារកំដៅភ្លើងហើយទៅជាកើតជំងឺហឺតដោយ អំណាចខំផ្លុំភ្លើងឱ្យឆេះ ឥតឈប់ឈរ ភ្នែកឡើងក្រហមដោយសារផ្សែងចូលស្ទើរតែមើលអ្វីពុំឃើញ ។ ទុក្ខត្រួតលើទុក្ខ តែគូកនរបស់គាត់ក៏កើតសេចក្ដីច្រណែននឹងគាត់ព្រោះគាត់នៅផ្ទះរាល់ថ្ងៃជាមួយនឹងប្រពន្ធ ។ គូកនគាត់បានព្រួតគ្នាប្រឆាំងនឹងគាត់ហើយតាមព្យាបាទគាត់ឥតឈប់ឈរ ។ កាលណាស៊ីមងាកបែរមុខចេញទៅឯណា គូកនគាត់ក៏លបបង់អំបិលមួយក្ដាប់ធំទៅក្នុងឆ្នាំង ហើយបបួលគ្នាលួចសើចព្រោះដឹងថា ដល់ពេលបាយយាយអៀងនឹងជេរមនុស្សគ្មានទោសនេះពុំខាន ។ ដោយអំណាចចិត្តកំហឹង គំនិងសុខបបួលគ្នារកកាប់មែកឈើនៅរស់ៗហើយមានជ័រផងយកមកឱ្យស៊ីមដុតដាំបាយ ។ លុះដុតឧសនោះទៅផ្សែងក៏ហុយពេញក្នុងផ្ទះយាយអៀងក៏រត់ចេញទៅមាត់ទ្វារ ហើយគេឮសូរគាត់ស្រែកជេរចុងភៅកំសត់ពីចម្ងាយរាប់ពុំឈ្នះ ។

ការហាត់នឿយនិងការលំបាកគ្រប់យ៉ាង បានធ្វើឱ្យបុរសទាំង ៤ រីតតែឆាប់ចាស់ គ្រាំគ្រាទៅទៀត ហើយជម្រុលទៅរកតែសេចក្ដីស្លាប់ពុំអាចនៅទ្រាំទ្រនឹងយាយអៀងដូច្នោះតទៅទៀតបានទេ ។ ថ្ងៃមួយនៅពេលដែលយាយអៀងទៅផ្សារយកស្វាយដែលខ្លួនបេះបានទៅលក់បុរសទំពែក ៤ នាក់ក៏ប្រជុំជំនុំគ្នា រួចសម្រេចចិត្តថា នឹងចេញពីទីនេះទៅទាំងអស់គ្នា ស្វែងរកខ្ញុំកំដរឱ្យមកបម្រើប្រពន្ធជំនួសខ្លួនរៀងខ្លួន ។

យុតក៏បាននិយាយថា :

- យើងឃើញកាន់តែចាស់ ហើយកាន់តែខ្សោយបន្តិចមួយថ្ងៃយើងមុខជានឹងស្លាប់បង់អសារ បើយើងឥតបានសម្រាកសោះដូច្នេះ ។

គិតដូច្នោះហើយ បុរសទំពែក ៤ នាក់ក៏ធ្វើដំណើរចេញដោយឥតចាំឱ្យយាយអៀងត្រឡប់មកពីផ្សារវិញទាន់ឡើយ ។ ហើយនៅថ្ងៃជាមួយគ្នានោះ គំនិតចង់បានខ្ញុំបម្រើកើតមាននៅក្នុងសន្ដានចិត្តនៃថៅចាក់ស្មុគម្នាក់ ។ ថៅចាក់ស្មុគនេះជាអ្នកប៉ិនប្រសប់ណាស់ខាងធ្វើស្មុគធ្វើកន្ត្រកអំពីក្បាបត្នោត ។ ដូច្នេះគាត់ក៏ឡើងទៅលើចុងត្នោតមួយខ្ពស់ហើយនឹកក្នុងចិត្តថា :

“ អញមិនត្រូវចុះទៅធ្វើស្មុគនេះឯដីទេ ព្រោះខ្លាចគេលបមើលស្គាល់ចំណេះអញ ដូច្នេះ ត្រូវតែអញនៅធ្វើស្មុគនៅលើចុងត្នោតនេះ កាលបើអញធ្វើបានច្រើនហើយ អញនឹងចុះពីចុងត្នោតយកស្មុគទៅលក់ ហើយអញនឹងទិញមនុស្សបម្រើម្នាក់មកប្រើ ” ។

នៅពេលដែលកំពុងច្រៀកស្លឹកត្នោតនោះ គាត់ក៏នឹកដូច្នេះទៀតថា “ បើមនុស្សបម្រើនោះ ត្រូវធ្វើការធូន់ បើប្រសិនជាវាបម្រើអញមិនសូវគាប់ប្រសើរទេ នោះប្រយ័ត្នត្រូវនឹងកែងជើងអញ ”។ កំពុងតែគិតដូច្នេះ បុរសក៏លើកជើងធាក់ហើយក៏រអិលខ្លួនធ្លាក់ពីដើមត្នោត ប៉ុន្តែ ជាសំណាងល្អនៅពេលធ្លាក់នោះ បុរសមានស្មារតីបានចាប់ចុងស្លឹកត្នោតជាប់នៅយោងតែលតោលៗ កណ្ដាលវាលមើលទៅដូចជាសត្វជ្រិង ។



នៅពេលនោះ មានទ្រមាក់ដរីម្នាក់ជិះដរីកាត់តាមនោះ ថៅចាក់ស្មុគ ក្រឡេកទៅឃើញក៏ស្រែកហៅយ៉ាងខ្លាំងថា “ លោកបងទ្រមាក់ដរី ! បើប្រសិនជាបងអាចជួយដាក់ខ្ញុំពីលើចុងត្នោតនេះបាន ខ្ញុំនឹងទៅបម្រើលោកអស់មួយជីវិត ” ។

កាលបើឮដូច្នេះ បុរសទ្រមាក់ដរីក៏មានចិត្តត្រេកអរជាខ្លាំង ។ គាត់ខំបះដរីគាត់យ៉ាងលឿនចូលទៅក្រោមដើមត្នោតហើយបញ្ឈប់ដរីនៅក្រោមនោះ រួចគាត់ក៏ឡើងឈរនៅខ្នងដរី ខំប្រឹងចំអើតចាប់ជើងថៅចាក់ស្មុគ ប៉ុន្តែនៅពេលដែលគាត់ក្រោកឈរនោះគាត់ខំប្រឹងទប់ខ្លួនឡើងញ័រគ្រប់សរសៃ ហាក់ដូចជាសញ្ញាគោះជំនិះគាត់ឱ្យដើរទៅមុខទៀតដរីយល់ដូច្នោះ ក៏ដើរទៅមុខទៀត ចោលទ្រមាក់ដែលកំពុងតោងជើងថៅចាក់ស្មុគជាប់ ។

បុរស ២ នាក់ក៏នៅតោងស្លឹកត្នោតនោះជាប់ មើលទៅឃើញហាក់ដូចជាផ្លែឈើពីរយ៉ាងធំវែង ។ សត្វក្អែកទាំងឡាយភ្ញាក់ផ្អើលនឹងទស្សនីយភាពយ៉ាងចំឡែកនោះ ក៏ហើរក្រឡឹងឆាបហើយស្រែកលាន់ឮទ្រហឹងអឹងកង ។

ថៅចាក់ស្មុគក៏កាន់តែធូន់ខ្លួនខ្លាំងឡើងទៅទៀត ហើយខំប្រឹងតោងស្លឹកត្នោតលុះត្រាតែក្បាបវាមុតចូលទៅក្នុងសាច់ស្រក់ឈាមមកលើមុខបុរសទ្រមាក់ដរី ជាហេតុធ្វើឱ្យបុរសខាងក្រោមនេះរីតតែភ័យញាប់ញ័រទៅទៀត ។

យល់ឃើញថាខ្លួនពុំអាចខំប្រឹងតោងធាងត្នោតបានទៀតទេ ថៅចាក់ស្មុគក៏អង្វរករថៅទ្រមាក់ដរីដូច្នេះថា « ចូរអ្នកលែងជើងខ្ញុំទៅ ខ្ញុំអស់កម្លាំងណាស់ហើយ ! ចូរលែងជើងខ្ញុំទៅបើមិនដូច្នេះទេយើងនឹងធ្លាក់ទៅដីស្លាប់ទាំងអស់គ្នា ” ។

មិនតែប៉ុណ្ណោះ ថៅចាក់ស្មុគបានស្រែកជេរហើយស្ដោះទឹកមាត់ដាក់ក្បាលទ្រមាក់ដរីជាច្រើនទៀតផង ប៉ុន្តែថៅទ្រមាក់ដរីត្រឡប់ជាស្រែកអង្វរករទៅថៅចាក់ស្មុគវិញថា “ឱលោកបងអើយ ! សូមលោកកុំលែងដៃឱ្យសោះ ។ បើប្រសិនជាលោកម្ចាស់ទ្រាំតោងលុះត្រាតែមានជនណា គេមកជួយដាក់យើងឱ្យរួចពីចុងត្នោត នោះខ្ញុំនឹងធ្វើជាខ្ញុំបម្រើលោកវិញលុះត្រាតែក្ស័យជីវិត ” ។

នៅពេលនោះ ស្រាប់តែលេចបុរសទំពែកយើង ៤ នាក់ ដែលស្វែងរកទាសៈសម្រាប់បម្រើប្រពន្ធខ្លួនទៅដល់ បុរសអស់សង្ឃឹមទាំងពីរនាក់ ស្រែកហៅបុរសទំពែកទាំងឡាយឱ្យចូលមកហើយនិយាយថា " ឱលោកឪពុកទាំងឡាយ សូមលោកឪពុកជួយយកអាសាខ្ញុំផង ខ្ញុំនឹងទៅនៅធ្វើខ្ញុំបម្រើលោកលុះត្រាអស់មួយជីវិត "។

បានឮដូច្នោះ បុរសទំពែក ៤ នាក់ក៏ត្រេកអរជាខ្លាំង ទើបយុតនិយាយទៅកាន់គូកនខ្លួនថា " យើងពុំដឹងមានមធ្យោបាយអី នឹងរកមនុស្សបម្រើឱ្យបាន ឥឡូវយើងបានជួបពីរនាក់នេះហើយ ។ ចូរយើងសន្ទឹងសំពត់ឡើងហើយម្នាក់ៗ កាន់មួយជ្រុងឈរពីក្រោមមនុស្សយោលទោងនេះ " ។ លុះធ្វើដូច្នេះហើយបុរសទំពែក ៤ នាក់ក៏ស្រែកហៅឱ្យបុរសពីរនាក់ទម្លាក់ខ្លួនចុះមក ប៉ុន្តែបុរសខាងក្រោមនេះពុំទាន់ដាច់ចិត្តហ៊ានទម្លាក់ខ្លួនមកហើយស្រែកប្រាប់មកចៅទំពែកដូច្នេះថា " ឱលោកឪពុកក្មេក ! តើលោកឪពុកមានកម្លាំងគ្រប់គ្រាន់ទេ ? លោកឪពុកសន្ទឹងសំពត់ស្រួលហើយឬ ?.... ប្រាកដហើយឬ ? "

ដើម្បីជាការប្រយ័ត្នទៅទៀត តាទំពែក ៤ នាក់ក៏យកជ្រុងសំពត់ចងជាប់ទៅនឹងករៀងៗខ្លួន រួចខំប្រឹងទប់ខ្លួនទាញសំពត់យ៉ាងអស់ទំហឹង រួចស្រែកទៅកាន់បុរសតែងតោងពីរនាក់នោះថា " ម្តងនេះតាធ្វើស្រួលបួលហើយ ចូរចៅទម្លាក់ខ្លួនមក!" ។

ចៅចាក់ស្មុគនិងចៅទ្រមាក់ដីរីក៏ទម្លាក់ខ្លួនមកចំកណ្តាលសំពត់ ប៉ុន្តែអនិច្ចាអើយទម្ងន់មនុស្សពីរនាក់នោះ បានកន្ត្រាក់ទាញក្បាលទំពែក ៤ នាក់ឱ្យមកទង្គិចគ្នាលាន់សូរតែផូស ។

សេចក្តីហេតុនេះ យុត គំ ស៊ឹម និងសុខ ក៏ក្ស័យជីវិតនៅពេលជាមួយគ្នានោះអស់ទៅ ។